**វីដេអូ**

តើហេតុអ្វីបានជាត្រូវមាន “ការស្វែងរកការគាំទ្រមតិ”?

នៅក្នុងស្ថានភាពជាច្រើន ប្រជាពលរដ្ឋអាចធ្វើឱ្យអ្វីៗផ្លាស់ប្តូរបាន តាមរយៈការសហការជាមួយ អាជ្ញាធរ អង្គការដទៃទៀត ឬក្រុមហ៊ុន/អាជីវកម្មនៅក្នុងសហគមន៍របស់ពួកគាត់។

<u>សូមវិភាគឧទាហរណ៍មួយ៖</u>

នៅក្នុងលក្ខខណ្ឌទាំងនេះ វាអាចធ្វើបាន ក្នុងការផ្តល់ការអប់រំកម្រិតបឋមសមស្របដល់កុមារ៖

ដំណោះស្រាយដែលល្អសម្រាប់បញ្ហានេះ គឺត្រូវពិនិត្យមើលដូចនេះ៖

វិធីមួយក្នុងការដោះស្រាយបញ្ហានេះ និងសម្រេចបានស្ថានភាពដែលយើងប្រាថ្នាចង់បាន គឺស្វែងរកមូលនិធិពីប្រភពក្នុងស្រុក/មូលដ្ឋាន ឬពីបរទេស ជ្រើសរើសគ្រូបង្រៀនស្ម័គ្រចិត្ត ផ្តល់សម្ភារៈដល់គ្រូបង្រៀន កសាងសាលារៀនឡើងវិញ និងហៅកុមារឱ្យត្រឡប់មកចូលរៀនវិញ។

យើងហៅវិធីដោះស្រាយតម្រូវការរបស់ក្រុមដែលកំពុងជួបការលំបាកនេះ (ក្នុងករណីនេះ គឺកុមារដែលកំពុងត្រូវការសាលារៀន) ថា “ការផ្តល់សេវា” ។

វិធីសាស្ត្រមួយទៀតក្នុងការដោះស្រាយបញ្ហានេះ រួមមានការកៀរគរមាតាបិតាសិស្ស និងអង្គការមូលដ្ឋានដទៃទៀត បើអាចធ្វើបានជាមុនសិន និងសូម្បីតែសមាគមមាតាបិតាសិស្ស នៅតាមសហគមន៍ ដែលមានបញ្ហាដូចគ្នា។

បើសិនជាអ្នកគាំទ្រទាំងនេះរកឃើញវិធីបញ្ចុះបញ្ចូលអ្នកដទៃ អង្គការ ឬក្រុមហ៊ុន/អាជីវកម្មឱ្យជឿបាន នោះការអំពាវនាវរកដំណោះស្រាយរបស់ពួកគាត់ នឹងមានឥទ្ធិពលកាន់តែខ្លាំង។

នៅពេលដែលពួកគាត់ធ្វើការរួមគ្នា ពួកគាត់អាចមានការគាំទ្រគ្រប់គ្រាន់ និងអំណះអំណាងល្អ ដើម្បីបញ្ចុះបញ្ចូលជនទាំងឡាយ ដែលអាចផ្លាស់ប្តូរស្ថានភាព ឱ្យធ្វើវាពិតប្រាកដបាន។ ក្នុងករណីនេះ ពួកគាត់បញ្ចុះបញ្ចូលអ្នកដឹកនាំអាជីវកម្ម នាយកសាលា និងអាជ្ញាធរមូលដ្ឋានមួយចំនួនក្នុងការដោះស្រាយបញ្ហា។

ជាចុងក្រោយ សេចក្តីសម្រេចមួយនឹងត្រូវបានធ្វើឡើង ក្នុងការបែងចែកមូលនិធិ សម្រាប់ការសាងសង់សាលារៀន ធានាថា គ្រូបង្រៀនត្រូវបានចាត់តាំងទៅបង្រៀននៅសាលារៀននោះ ហើយសាលារៀនទទួលបានសម្ភារៈសិក្សាដែលចាំបាច់។

យើងហៅអភិក្រមនេះថា “ការស្វែងរកការគាំទ្រមតិ” ។ អភិក្រមការស្វែងរកការគាំទ្រមតិ ព្យាយាមធ្វើឱ្យមានឥទ្ធិពលជាវិជ្ជមានលើសេចក្តីសម្រេច ដែលត្រូវបានធ្វើឡើងលើបញ្ហា។ អភិក្រមនេះ អាចហៅម្យ៉ាងទៀតថា “ការធ្វើឱ្យមានឥទ្ធិពលលើគោលនយោបាយ” ក៏បាន។

ដូច្នេះ មានអភិក្រមពីរខុសគ្នា៖ ការផ្តល់សេវា និងការស្វែងរកការគាំទ្រមតិ។ អភិក្រមទាំងពីរ អាចមានប្រសិទ្ធភាព ក្នុងការដោះស្រាយដល់ក្រុមដែលទទួលរងផលប៉ះពាល់ពីបញ្ហា។ ប៉ុន្តែ អភិក្រមទាំងពីរនេះ មានលក្ខណៈសម្គាល់ពិសេសខុសគ្នា។

**ការបញ្ចាំងស្លាយជាអត្ថបទ**

[សន្លឹកទី១]

តើហេតុអ្វីបានជាត្រូវមាន “ការស្វែងរកការគាំទ្រមតិ” ?

[សន្លឹកទី៣]

នៅក្នុងស្ថានភាពជាច្រើន ប្រជាពលរដ្ឋអាចធ្វើឱ្យអ្វីៗផ្លាស់ប្តូរបាន តាមរយៈការសហការជាមួយអាជ្ញាធរ អង្គការផ្សេងទៀត ឬក្រុមហ៊ុន/អាជីវកម្ម នៅក្នុងសហគមន៍របស់ពួកគាត់។

[សន្លឹកទី៥]

សូមវិភាគឧទាហារណ៍មួយៈ

[សន្លឹកទី៨]

ការផ្តល់សេវា

[សន្លឹកទី៩]

ការធ្វើឱ្យមានឥទ្ធិពលលើគោលនយោបាយ

ការបែងចែកថវិកាតាមនាយកដ្ឋាន/ផ្នែក

អាជ្ញាធរមូលដ្ឋាន

(តារាងស្លាយទី៩)

វិស័យអប់រំ

សាធារណការ

ការពារជាតិ

មហាផ្ទៃ និងរដ្ឋាភិបាលមូលដ្ឋាន

សង្គមកិច្ច

សុខាភិបាល

កសិកម្ម

ការដឹកជញ្ជូន និងសារគមនាគមន៍ (ទំនាក់ទំនង)

បរិស្ថាន

តុលាការ